HONEYCOMB 3/2 (April 2002): 1–9



# "Such as these"— A Framework for Understanding our Children

*Heather FORBES*

When I was pregnant with my first child, it seemed that everyone—family, friends, even complete strangers—felt compelled to give me child-rearing advice. Some of my most interesting conversations on this topic happened at the local supermarket, while picking through broccoli or beans alongside women of varying cultural backgrounds. These fellow shoppers gave me a world of advice about my upcoming baby, starting with predictions about its gender:

"Your nose is wider now than a few weeks ago, so you're having a girl!"
"Is the baby active? Then you must be having a boy!"
"Your body is shaped like a pear, not an apple, so you must be having a girl."

Naturally, advice from others became more serious and more frequent as the baby's due date drew near. Relatives talked about baby care. Church members recommended books they had read. Our doctor registered us for childbirth education classes. Four years later, here in Cambodia, the advice continues. My neighbor across the road tells

me how to dress my daughters for the heat and mosquitoes. On a recent trip to China, we were often scolded for not putting enough layers of clothing on the kids.

Why do so many of us have something to say about parenting? The volume of advice so readily given hints at the profound nature of the job. It is at once the most sobering and most joyful of undertakings. When our first child was born, I lost a lot of sleep, but not only because of a wakeful, needy baby. In those weeks, even after we had put her down to sleep, my mind continued to churn with the overwhelming wonder of this new life, and the responsibilities ahead of us. God had given us the privilege of bringing a whole person, with an eternal soul, into this world, and her tiny presence in our home left me awestruck.

Thankfully, the God who gave us this awesome responsibility has also provided guidelines for the job. Proverbs 22:6 says, "Train a child in the way he should go, and when he is old he will not turn from it." God would not have us underestimate the impact we have on our children. This verse tells us that the way we parent our children is bound to have long-term effects on them, whether for their good or ill.

Dr. William Sears, one of America's most renowned pediatricians and an outspoken Christian, says that the training of a child begins from the moment of her birth and involves every interaction we have with her. He refers to this task of training a child as the process of "discipline." Discipline, he says, is a process of "imparting God's Word to such a degree that it becomes part of each child's inner self, his inner controls, his base of operations ... in short ... to instill a sense of direction."[1]

If, then, we are always in the process of instilling a sense of direction in our children, whether consciously or not, how do we make sure we are guiding them in "the way [they] should go"? Two interpretations of Proverbs 22:6 have been helpful in my efforts to discipline my own children. First, it can be read as a call to train our children to follow God's commandments. A second way to understand the phrase "in the way she should go" is as a reference to God's *specific*,

---

[1]William Sears, *Christian Parenting & Child Care* (Nashville: Broadman & Holman, 1997), 328.

*unique* plan for each child. In other words, nurturing our children according to their own "bent," or the nature God has given them. I believe both interpretations are helpful: that as we teach our children to walk in God's ways, we should do so with recognition of their God-given uniqueness. However, what are some of the principles that will enable us to succeed at this awesome challenge?

## Becoming a Student of Your Child

Instilling a sense of godly direction in a child begins with getting to know him or her and establishing a secure relationship built on trust. Discipline, Dr. Sears says, is something done *with*—not *to*—a child. Early in our marriage, my husband and I heard a piece of practical marriage advice that has proven to be a gold mine for promoting understanding, renewing loving feelings and enabling communication between the two of us. That statement was: study your spouse. Likewise, studying our children—finding out what really makes them "tick"—will lay a foundation of understanding that keeps our communication lines open, even as they grow and change. This will enable us to establish a climate in which loving, effective discipline can thrive.

## A Child is a Whole Person

Our study of our children must begin with what God says about them. A foundational principle in understanding our children is that every child is a person created in God's image.

> So God created humankind in his own image,
> in the image of God he created him;
> male and female he created them.[2]

Like the first humans and all that have come since, children are created in and for relationships with their creator, with other humans, and with the world around them. The highest commandments, identified by Jesus, are about those relationships.

---

[2]Gen 1:27.

> "The most important [commandment]," answered Jesus, "is this: 'Hear, O Israel, the Lord our God, the Lord is one. Love the Lord your God with all your heart and with all your soul and with all your mind and with all your strength.' The second is this: 'Love your neighbor as yourself.' There is no commandment greater than these."[3]

A child, like all humans, is a whole person—a physical, mental, emotional, social and moral being. We can see from the above verses that God created children, as whole human beings, to live in whole relationships with God and others, involving every aspect of their personhood.

Parents of very young children might ask how we can possibly relate on all these levels to infants who seem to have constant physical needs but no words to express thoughts. Once again, the Bible is encouraging in this endeavor. To Judah's prophet Jeremiah, God confided: "Before I formed you in the womb I knew you."[4] Israel's King David understood that:

> My frame was not hidden from you,
>     when I was being made in the secret place.
> When I was woven together in the depths of the earth,
>     your eyes saw my unformed body.
> All the days ordained for me
>     were written in your book
>     before one of them came to be.[5]

Pastor Gary Chapman and physician Ross Campbell encourage parents that an infant is capable of receiving care on more than just the physical level. They say that a

> great deal of research indicates that the emotional foundation of life is laid in the first eighteen months of life, particularly in the mother/child relationship. The "food" for future emotional health is physical touch, kind words, and tender care.[6]

---

[3]Mark 12:30–31.

[4]Jer 1:5.

[5]Ps 139:15–16.

[6]Gary Chapman and Ross Campbell, *The Five Love Languages of Children* (Chicago: Northfield, 1997), 24.

Such nurture will enable the child to have healthy trusting relationships with God and with others as he or she grows.

Linguists tell us that a young child's mind is processing verbal input even when we don't see it happening—that a child receives and understands much more than he says. Because of this, Dr. Sears says your child will begin to have a concept of God before being able to articulate it. "Your child will understand better the concept of God if she has been saturated with hearing about God from birth. By the time she is two years old, she hears the words God and Jesus spoke in association with love and protection. By the time she is three years old, she feels God's presence."[7]

Seeing my own daughters' young responses to Christ has convinced me of this. Dylan, now four, has been listening to Bible stories since before she was one year old, and she now knows them backwards and forwards. Moreover, her sensitive spirit has internalized their truth and she is cultivating a real relationship with God. At times, we have seen her pause in the middle of what she is doing, and when we ask, she says that she is "listening to God." Two-year-old Zoe often initiates prayer at our dinner table and before bedtime. One night last year she woke up crying for our night guard, and we prayed for him. The next day we found out he had been injured in a car accident that same night. Seeing this type of spiritual sensitivity in our young children should encourage us to involve God-talk at the heart of our family lives. Pray, tell stories, and sing together, with the confidence that God's spirit is moving in your children. Or, in the words of Deuteronomy 6:6–9,

> These commandments that I give you today are to be upon your hearts. Impress them on your children. Talk about them when you sit at home and when you walk along the road, when you lie down and when you get up. Tie them as symbols on your hands and bind them on your foreheads. Write them on the doorframes of your houses and on your gates.

---

[7]Sears, *Christian Parenting*, 332.

## A Child is a Unique Person

While children are whole human beings and should be treated as such, each child is also unique. It is easy to interpret a child's perspective as less virtuous or important than an adult's; in a world where adults hold the power and authority, a child's opinion or needs are easily forgotten or discounted. On the other hand, God has given children special position in his kingdom, and throughout the gospels Jesus affirmed the value of the "least of these." In the gospel of Mark, we see Jesus contradicting the disciples' demeaning assumptions about children who came to see him. "Let the little children come to me," he says, "for the kingdom of God belongs to such as these."[8] In the story of the miraculous feeding of the crowd, it is a child's gift, a small lunch of bread and fish, that Christ used to bless thousands of adults.[9] The radical choice of God to be incarnated among us as an infant first, rather than appearing as an adult, speaks volumes about the value he ascribes to the nature of a child.

People who have good rapport with children often interact with them at the children's own eye level. Literally getting down on a child's level during times of play, comfort, and correction helps the adult see from the child's perspective and communicates understanding to the child. When Christian adults make the effort to get on the level of the children in our communities and incorporate some of their perspective into our community life and worship, we become more like the kingdom of God. Pastor Jim Brenneman of Pasadena Mennonite Church comments: "The church can only be a better place if, every now and again, we sit at our children's feet to listen to what they have to teach us."[10]

Children are unique not only as a group, but also as individuals. Psalm 139 is a beautiful testament to the intimate craftsmanship of a creator who "knit [the child] together in [his] mother's womb" and who declares each child "fearfully and wonderfully made." Our discipline should recognize the uniqueness of each child. What my

---

[8]Mark 10:14.

[9]John 6:9.

[10]James E. Brenneman, Sermon 346, 27 February 2000.

husband and I learned about parenting through our sensitive, creative older daughter has not always been helpful with her spunky, extroverted little sister.

An exciting framework for conducting "research" on our children is to discover the unique ways they receive and give love. This is an idea promoted in several Christian child-raising books. One set of these "love languages"[11] includes physical touch, words of affirmation, quality time, gifts, and acts of service. Each culture might have its own categories of expressing and receiving love, or at least different variations within these categories. However, for all parents, it is good to ask ourselves: Do I know what really communicates love to my child? Have I noticed how my child most consistently expresses love to others? Training up a child in the way he should go can best be done when we have made the effort to know and affirm our children, in their unique gifts and personalities, just as God knows us intimately and knows best how to train us. Only then can we help them develop their gifts and communicate our love most clearly to them.

Learning our children's specific inner workings will help us understand reasons behind common areas of conflict with them. For example, I recently came to understand that a major source of tension between my daughter and me relates to the different speeds at which we operate. I am fast-paced and decisive; she is thoughtful, needing more time between transitions. Now that I understand this, I can better distinguish between what is a moral issue and what is just a difference in personality. If it is a personality conflict, depending on the situation, I can try to accommodate Dylan, since she is the one with less understanding, and by doing so, model humility and express love to her. Or, if it is not possible to accommodate her, I can try to teach her to adjust according to the situation, but do so gently, understanding her need for transition time.

---

[11]Chapman and Campbell, *Five Love Languages*, 7.

## A Child is a Person in Need of Direction

In order to know our children as God knows them, we must recognize that just as they are designed by God as whole and unique people with potential for relationship with God and humans, so also they are also fallen people who, like the rest of us, need redemption. "Folly is bound up in the heart of a child," says Proverbs 22:15. Who of us with a two- or three-year-old doesn't know this? Sometimes the folly I see demonstrated in my kids is only an area of poor judgment, like jumping up and down while riding a cyclo in traffic, or running into the street during play. But other times the issue is a moral one. Discipline, or guidance, in times of correction is one of the most challenging aspects of our parenting role. But it is essential in order to guide the child into her God-given potential and into the blessing of walking with God.

To write about the specifics of correction is not my intention in this article. However, as in all aspects of discipline, keeping open communication lines through a continuing study of your child is essential. The sustained effort we put into knowing our children will assist in this aspect of discipline as well. For the kind of communication that springs from a relationship built on trust will help us to:

- approach correction within the context of the goal of all discipline: to impart understanding and build godly character in the child.[12]
- present our children with clear, consistent choices and consequences in a way they can comprehend.
- create structure and conditions in our homes that encourage desirable behavior.

This will help us to maintain the right attitude in our correction, so that we do not act out of anger, but rather with the self-control that mirrors God's own correction of his children.

---

[12]See Heb 12:10–11.

## The Power of a Parent's Influence

We have seen that God has a lot to say about who a child is: made in the image of God; a whole person with all the traits of personhood; unique in childlike nature, and created one-of-a-kind; capable of relationship but needing redemption to live in right relationship with God and neighbor. With all of these basics in place, Sears invites us to take up the challenge of studying our children, as a gardener knows the plants in his garden. This means to learn the right climate for best raising our children, and to be aware of the kinds of weeds that our children are especially susceptible to. Approaching discipline in this way, our guidance will be neither overly permissive nor abusive, because we will be viewing them with the wise and grace-filled eyes through which God sees us, and guiding them in his wisdom.

សំណុំនិក្ខេបបទ ៣/២ (មេសា ២០០២)៖ ១០-២៤



# "ដូចជាកូនក្មេងទាំងអស់នេះ" គម្រោងការសំរាប់ស្វែងយល់អំពីកូនរបស់យើង

*អ្នកស្រី ហេឌរ ហ្វបស៍*

នៅពេលដែលខ្ញុំមានផ្ទៃពោះកូនដំបូងរបស់ខ្ញុំ គឺវាហាក់បីដូចជាមនុស្សគ្រប់គ្នាទាំងអស់ មិនថា ក្រុមគ្រួសារ មិត្តភក្តិ សូម្បីមនុស្សមិនដែលស្គាល់គ្នាសោះ ក៏ខំមកជួយផ្តល់ដំបូន្មានដល់ខ្ញុំស្តីពីការបីបាច់ថែទាំកូនដែរ ។ ការសន្ទនាដ៏គួរឲ្យចាប់អារម្មណ៍របស់ខ្ញុំចំពោះរឿងនេះ គឺនៅក្នុងផ្សារទិញឥវ៉ាន់ នៅពេលដែលខ្ញុំកំពុងរកមើលទិញខាត់ណា ឬទិញសណ្តែកក្នុងចំណោមស្ត្រីជាច្រើនដែលមានសាវតានៃទំនៀមទម្លាប់ផ្សេងៗពីគ្នា ។ អ្នកដែលបានដើរទិញឥវ៉ាន់នៅផ្សារជាមួយគ្នា បានឲ្យដំបូន្មានយ៉ាងច្រើនធំធេងណាស់ស្តីពីកូនរបស់ខ្ញុំដែលបំរុងនឹងកើតមក ដោយអ្នកខ្លះចាប់ផ្តើមទាយពីភេទរបស់កូននោះដោយនិយាយថា៖

"ច្រមុះរបស់អ្នកទូលាយជាងប៉ុន្មានអាទិត្យមុន ដូច្នេះអ្នកប្រាកដជាបានកូនស្រីហើយ!"

"តើកូនបំរះខ្លាំងទេ? អ៊ីចឹងប្រហែលជាបានកូនប្រុសហើយ!"

"ពោះរបស់អ្នកនៅពេលមានទម្ងន់អ៊ីចឹងទៅរាងដូចជាផ្លែសារី មិនដូចជាផ្លែប៉ោមទេ ដូច្នេះអ្នកប្រាកដជាបានកូនស្រីហើយ ។"

តាមធម្មតា ជំបូន្មានពីអ្នកដទៃកាន់តែប្រាកដប្រជាឡើង និងកាន់តែញឹកញាប់ឡើងៗ នៅពេលដែលថ្ងៃប្រសូតកាន់តែជិតមកដល់ ។ ញាតិសន្តាននាំគ្នានិយាយពីការថែទាំដល់ទារក ។ សមាជិកក្រុមជំនុំណែនាំឲ្យអានសៀវភៅដែលគេធ្លាប់បានអាន ។ វេជ្ជបណ្ឌិតរបស់យើងបានចុះឈ្មោះឲ្យយើងចូលរៀនពីរបៀបថែទាំកូន ។ មកដល់ប្រទេសខ្មែរបួនឆ្នាំក្រោយមក ជំបូន្មាននោះនៅតែបន្តទៀត ។ អ្នកជិតខាងរបស់ខ្ញុំដែលរស់នៅទល់នឹងផ្ទះរបស់ខ្ញុំបានប្រាប់ខ្ញុំពីរបៀបដែលខ្ញុំត្រូវស្លៀកពាក់ឲ្យកូនស្រីរបស់ខ្ញុំ ដ្បិតធាតុអាកាសក្តៅ និងមានមូសច្រើន ។ នៅពេលថ្មីៗនេះខ្ញុំបានទៅលេងនៅប្រទេសចិន យើងតែងតែទទួលនូវការស្តីបន្ទោសដោយមិនបានពាក់អាវឲ្យបានច្រើនជាន់ឲ្យកូនៗរបស់យើង ។

ហេតុអ្វី បានជាយើងភាគច្រើនតែងតែមានពាក្យនិយាយពីការបីបាច់ថែទាំកូនដូច្នេះ? ទំហំដ៏ធំធេងនៃជំបូន្មាននេះប្រុងប្រៀបជាស្រេច ដើម្បីបង្ហើបប្រាប់ពីលក្ខណៈស៊ីជម្រៅនៃការងារនោះ ។ ជំបូន្មានទាំងនោះភាគច្រើនយើងទទួលយកភ្លាមដោយអំណរ និងយកជាការប្រាកដប្រជាភ្លាមតែម្តង ។ នៅពេលកូនច្បងរបស់យើងកើត ខ្ញុំដេកមិនលក់សោះ ប៉ុន្តែមិនមែនដោយសារកូនយំទារបៅ ឬត្រូវការផ្លាស់កន្ទបប៉ុណ្ណោះទេ ។ នៅក្នុងពេលប៉ុន្មានអាទិត្យនោះ សូម្បីតែនៅពេលដែលខ្ញុំបានដាក់វាឲ្យដេកហើយក្តី ក៏អារម្មណ៍របស់ខ្ញុំកំពុងជ្រួលច្របល់ឆ្ងល់ចំពោះជីវិតថ្មីរបស់កូនតូចនេះ និងការទទួលខុសត្រូវទាំងឡាយរបស់យើងចំពោះកូននេះនៅថ្ងៃខាងមុខ ។ ព្រះជាម្ចាស់បានផ្តល់ឲ្យយើងនូវឯកសិទ្ធិនៃការនាំយកនូវមនុស្សមួយរូប ដែលមានព្រលឹងអស់កល្បជានិច្ចចូលមកក្នុងលោកយើងនេះ ហើយព្រមទាំងវត្តមានដ៏នៅតូចរបស់គេនៅក្នុងផ្ទះរបស់យើង យើងខ្ញុំមានការកោតខ្លាចចំពោះព្រះជាខ្លាំង ។

អរព្រះគុណចំពោះព្រះជាម្ចាស់ ដែលព្រះអង្គបានប្រគល់ការទទួលខុសត្រូវដែលប្រកបដោយការកោតខ្លាចនេះមកយើង ព្រមទាំង

ផ្តល់ឲ្យយើងនូវគោលការណ៍ណែនាំក្នុងធ្វើការងារនេះ ។ សុភាសិត ២២:៦ បានថែងថា៖ "ចូរបង្ហាត់កូនក្មេងឲ្យប្រព្រឹត្តតាមផ្លូវដែលគួរប្រព្រឹត្ត នោះវានឹងមិនលះបង់ពីផ្លូវនោះដរាបដល់ចាស់" ។ ព្រះជាម្ចាស់មិនបានឲ្យយើងព្រងើយកន្តើយចំពោះការអប់រំកូនរបស់យើងនោះឡើយ ។ ខគម្ពីរនេះប្រាប់យើងពីរបៀបដែលយើងត្រូវបីបាច់ថែរក្សាកូន គឺវាមានឥទ្ធិពលយូរអង្វែងចំពោះជីវិតរស់នៅរបស់កូនយើង មិនថាកូននោះជាកូនមានសុខភាពល្អ ឬកូននោះឈឺអ្វីនោះឡើយ ។

វេជ្ជបណ្ឌិត *វីល្លាម ស៊ា* (William Sears) ជាអ្នកល្បីល្បាញម្នាក់ផ្នែកជម្ងឺកុមារនៅប្រទេសអាមេរិក ហើយក៏ជាគ្រីស្ទបរិស័ទដែលមានវេហារនិយាយថា ការស្តីប្រដៅដល់កូនចាប់ផ្តើមឡើងតាំងពីកូននោះកើតឡើងភ្លាមម្ល៉េះ គឺវាទាក់ទងទៅនឹងគ្រប់ផ្នែកនៃការដែលយើងធ្វើអ្វីៗជាមួយកូននោះ ។ គាត់បាននិយាយយោងទៅដល់ការងារហ្វឹកហ្វឺនដល់កូន គឺជាដំណើរការ "ប្រដៅតម្រង់" ។ គាត់និយាយថា ការប្រដៅតម្រង់នោះ គឺជា "ការបញ្ចូលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដល់គំនិតមួយដែលអាចក្លាយទៅជាផ្នែកមួយរបស់កូន គឺជាការគ្រប់គ្រងផ្នែកខាងក្នុងរបស់ក្មេងផ្អែកលើកិច្ចប្រតិបត្តិការនានា និយាយឲ្យខ្លីទៅគឺចាក់ឫសនៃគំនិតដែលមានទិសដៅនៅក្នុងគំនិតរបស់គេ ។"[1]

អ៊ីចឹងបើសិនយើងស្ថិតនៅក្នុងដំណើរការនៃការចាក់ឫសនៅក្នុងគំនិតរបស់កូនយើងឲ្យគេចេះមានគំនិតដែលប្រកបទៅដោយទិសដៅនោះ មិនថាឡើយយើងធ្វើការទាំងដឹងខ្លួន ឬមិនដឹងខ្លួននោះឡើយ តើយើងដឹងច្បាស់ដោយរបៀបណាបាន ថាយើងកំពុងដឹកនាំកូនរបស់យើង "ដើរក្នុងផ្លូវមួយដែលគេគួរតែដើរនោះ"? មានការបកស្រាយពីរយ៉ាងនៅត្រង់បទគម្ពីរ

---

[1] William Sears, *Christian Parenting & Child Care* (Nashville: Broadman & Holman, 1997), 328.

សុភាសិត ២២:៦ ដែលមានប្រយោជន៍មែនទែនដល់ការខំប្រឹងប្រែងរបស់ខ្ញុំក្នុងការស្ដីប្រដៅកូនរបស់ខ្ញុំផ្ទាល់ ។ ទីមួយ បទគម្ពីរនេះគ្រាន់តែអានទៅដូចជាការត្រាស់ហៅមួយបែបពីព្រះជាម្ចាស់ ដើម្បីហ្វឹកហ្វឺនកូនរបស់យើងឲ្យចេះដើរតាមព្រះរាជបញ្ញារបស់ព្រះជាម្ចាស់ ។ របៀបទីពីរក្នុងការយល់ពីឃ្លាដែលបានចែងថា "ផ្លូវដែលគួរដើរ" នោះគឺទាក់ទងទៅនឹងផែនការដ៏ជាក់លាក់របស់ព្រះជាម្ចាស់យ៉ាងពិសេសគ្មានពីរសំរាប់កុមារម្នាក់ៗ ។ គឺមានន័យថា ការមើលថែទាំកូនរបស់យើងស្របតាម "ទំនោរ" របស់វាផ្ទាល់ ឬតាមលក្ខណៈរបស់ព្រះជាម្ចាស់ដែលព្រះអង្គបានផ្ដល់ឲ្យគេ ។ ខ្ញុំជឿថាការបកស្រាយទាំងពីរនេះមានប្រយោជន៍គឺ៖ មានន័យថានៅពេលដែលយើងបង្រៀនកូនរបស់យើងឲ្យដើរតាមផ្លូវរបស់ព្រះជាម្ចាស់ នោះយើងត្រូវទទួលស្គាល់ពីលក្ខណៈពិសេសដែលព្រះជាម្ចាស់ប្រទានឲ្យគេ ។ ទោះបីជាយ៉ាងណាក៏ដោយ តើមានគោលការណ៍អ្វីខ្លះទៀត ដែលអាចជួយឲ្យយើងទទួលជោគជ័យក្នុងការទទួលខុសត្រូវដោយគោរពកោតខ្លាចនេះបាន?

## ការក្លាយទៅជាសិស្សរបស់កូនខ្លួនឯង

ការចាក់ឫសក្នុងគំនិតដែលមានទិសដៅប្រកបដោយការកោតខ្លាចព្រះ ចំពោះកុមារចាប់ផ្ដើមឡើងដោយការស្គាល់ចរិតលក្ខណៈរបស់កូននោះ និងការបង្កើតឲ្យមានភាពដែលអាចទុកចិត្តបានចំពោះទំនាក់ទំនង ។ វេជ្ជបណ្ឌិត *ស៊ា* មានប្រសាសន៍ថា ការប្រដៅតម្រង់កូនចៅ គឺជាការងារដែលត្រូវធ្វើជាមួយកូន មិនមែនជាការធ្វើសំរាប់កូននោះទេ ។ មុនពេលយើងរៀបការប្ដីរបស់ខ្ញុំ និងខ្ញុំបានពុះពារឧបសគ្គសំខាន់ៗខ្លះស្ដីពីអាពាហ៍ពិពាហ៍ដែលបង្ហាញឲ្យឃើញថានោះជាអណ្ដូងរ៉ែមាស ដែលយើងត្រូវខំជីកកាយរកការយល់ដឹង និងការកែលំអនូវអារម្មណ៍ស្រឡាញ់ឲ្យថ្មីឡើងរហូត និងជំរុញឲ្យមានការប្រាស្រ័យទាក់ទងរវាងយើងទាំងពីរកាន់តែប្រសើរឡើង ។ ការថ្លែងប្រាប់ពី

ដំបូន្មាននោះគឺ៖ ចូររៀនឲ្យស្គាល់ពីដៃគូជីវិតរបស់អ្នក ។ ដូចគ្នានេះដែរ ចូរយើងរៀនឲ្យស្គាល់ពីនិស្ស័យលក្ខណៈរបស់កូនយើង គឺមានន័យថា ការស្វែងរកនូវអ្វីដែលពិតជាធ្វើឲ្យកូននោះ "ជាមនុស្សល្អ" ការនេះនឹងជួយចាក់គ្រឹះដល់ការយល់ដឹងដែលអាចជួយឲ្យយើងមានឱកាសប្រាស្រ័យទាក់ទងបានរហូត ទោះបីកូននោះគេធំឡើង និងមានការផ្លាស់ប្តូរយ៉ាងណាក៏ដោយ ។ ចំពោះការយល់ដឹងនេះនឹងជួយឲ្យយើងអាចបង្កើតឡើងនូវសេចក្តីស្រឡាញ់ដល់កំពូលដែលមានប្រសិទ្ធិភាពដល់ការប្រដៅតម្រង់ដ៏ប្រកបដោយជោគជ័យ ។

## កុមារគឺជាបុគ្គលពេញលក្ខណៈ

ការសិក្សាស្រាវជ្រាវឲ្យស្គាល់កូនរបស់យើង ត្រូវតែចាប់ផ្តើមឡើងជាមួយនឹងអ្វីៗដែលព្រះជាម្ចាស់មានព្រះបន្ទូលស្តីអំពីកូននោះ ។ គោលការណ៍គ្រឹះដ៏សំខាន់ក្នុងការស្វែងយល់ពីកូនរបស់យើងនោះគឺ កុមារទាំងឡាយជាមនុស្សដែលព្រះជាម្ចាស់បង្កើតមកជារូបឆ្លុះរបស់ព្រះអង្គ ។

> ទ្រង់ក៏បង្កើតមនុស្សឲ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឲ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី ។[២]

ដូចជាមនុស្ស និងរបស់ទាំងអស់ដែលព្រះជាម្ចាស់បង្កើតមក កុមារទាំងឡាយក៏ព្រះអង្គបង្កើតមកសំរាប់ឲ្យគេប្រាស្រ័យទាក់ទងជាមួយនឹងព្រះអាទិកររបស់គេ ព្រមទាំងប្រាស្រ័យទាក់ទងជាមួយមនុស្សដទៃទៀត និងពិភពលោកដែលនៅជុំវិញពួកគេដែរ ។ បញ្ញត្តិដ៏សំខាន់ជាងគេបំផុតដែលព្រះយេស៊ូបានបង្ហាញឲ្យឃើញនោះ គឺស្តីអំពីទំនាក់ទំនងទាំងនោះឯង ។

---

[២] *លោកុ. ១:២៧*

ព្រះយេស៊ូមានបន្ទូលឆ្លើយថា ឯបញ្ញត្តិដែលសំខាន់ជាងគេនោះ គឺថា៖ "ចូរស្តាប់ចុះ អ៊ីស្រាអែលអើយ ព្រះអម្ចាស់ជាព្រះនៃយើងខ្ញុំ ទ្រង់ជាព្រះអម្ចាស់តែមួយព្រះអង្គទ្រង់ ហើយឯងត្រូវស្រឡាញ់ដល់ព្រះអម្ចាស់ជាព្រះនៃឯង ឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង អស់អំពីគំនិត ហើយអស់អំពីកម្លាំងនៃឯង" នោះហើយជាបញ្ញត្តិទីមួយ ឯបញ្ញត្តិទីពីរក៏បែបដូចគ្នាគឺថា "ត្រូវឲ្យស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង គ្មានបញ្ញត្តិណាទៀតធំជាងបទទាំងពីរនេះទេ" ។[៣]

កុមារមានលក្ខណៈជាមនុស្សពេញលេញដូចជាមនុស្សទាំងអស់ដែរ គឺគេមានរូបកាយ ចិត្ត សតិអារម្មណ៍ ការទាក់ទងក្នុងសង្គម និងផ្នែកសីលធម៌ ។ យើងអាចមើលឃើញនៅក្នុងខគម្ពីរខាងលើនោះដឹងរួចហើយថា កុមារទាំងឡាយព្រះជាម្ចាស់ជាអ្នកបង្កើតគេមកជាមនុស្សគ្រប់លក្ខណៈ ដើម្បីឲ្យគេរស់នៅក្នុងទំនាក់ទំនងគ្រប់លក្ខណៈជាមួយព្រះជាម្ចាស់ និងជាមួយអ្នកដទៃ ដែលទាក់ទងគ្រប់វិស័យនៃលក្ខណៈជាមនុស្សរបស់គេទាំងស្រុង ។

ឪពុកម្តាយដែលមានកូននៅតូចៗ ប្រហែលជាអាចសួរថា ធ្វើម៉េចអាចឲ្យយើងទាក់ទងទៅគ្រប់ផ្នែករបស់កូនតូចៗទាំងនោះបាន ដោយហាក់បីដូចជាគេត្រូវការផ្នែករូបកាយនោះរហូត តែគ្មានពាក្យសំដីណាមកបញ្ជាក់ប្រាប់ពីគំនិតរបស់គេឡើយ ។ ចំពោះព្យាការីរបស់ជនជាតិយូដា គឺលោកយេរេមា ព្រះជាម្ចាស់បញ្ជាក់យ៉ាងច្បាស់ថា៖ "មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយ នោះអញស្គាល់ឯងហើយ..."[៤] ស្តេចអ៊ីស្រាអែលបានយល់យ៉ាងច្បាស់ថា៖

---

[៣] *ម៉ាកុស ១២:២៩-៣១*

[៤] *យេរេមា ១:៥*

កាលទូលបង្គំកើតមាននៅទីកំបាំង ហើយបានសូនធ្វើបែបចម្លែកៗ នៅទីទាបនៃផែនដី នោះគ្រោងកាយរបស់ទូលបង្គំមិនកំបាំងនឹងទ្រង់ទេ ព្រះនេត្រទ្រង់បានឃើញធាតុនៃទូលបង្គំក្នុងកាលដែលមិនទាន់មានរូបរាងនៅឡើយ ទាំងអស់បានកត់ទុកក្នុងបញ្ជីរបស់ទ្រង់...[៥] ។

លោកគ្រូគង្វាល *ហ្គារី ឆែបមិន* និងលោកវេជ្ជបណ្ឌិតរ៉ូស *ខាំបែល* បានលើកទឹកចិត្តដល់ឪពុកម្តាយថា កូនតូចៗគេមានសមត្ថភាពនឹងទទួលការថែទាំពីឪពុកម្តាយលើសពីកំរិតផ្នែករូបកាយទៅទៀត ។ លោកទាំងពីរបាននិយាយថា យោងតាមការស្រាវជ្រាវដ៏ធំមួយបានបង្ហាញថា គ្រឹះសំខាន់នៃអារម្មណ៍របស់ក្មេងក្នុងអំឡុងដែលគេមានអាយុ១៨ខែដំបូង ជាពិសេសនៅក្នុងទំនាក់ទំនងរវាងម្តាយនឹងកូន ។ "ចំណីអាហារ" ដ៏ល្អសំរាប់សុខភាពផ្នែកអារម្មណ៍ គឺកើតឡើងដោយសារបីបមថ្នមថៃ ការប្រើពាក្យពិរោះ និងការថ្នាក់ថ្នមយ៉ាងស្រទន់ពីឪពុកម្តាយ ។[៦]

ការបីបាច់ថ្នាក់ថ្នមបែបនោះ អាចជួយឲ្យកុមារមានទំនុកចិត្តក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយអ្នកដទៃនៅពេលដែលកូននោះធំឡើង ។

លោក *លីងហ្វ៊ីស* ប្រាប់យើងថា គំនិតរបស់កុមារទទួលបានដោយសារការនិយាយ ទោះបីជាគេមិនបានឃើញការនោះកើតឡើងនៅចំពោះមុខគេក៏ដោយ គឺមានន័យថាកុមារនោះគេទទួលបាន និងយល់បានច្រើនជាងអ្វីដែលអាចនិយាយចេញមកដោយខ្លួនគេបាន ។ ដោយសារតែហេតុនេះ

---

[៥] *ទំនុក.១៣៩:១៥-១៦*

[៦] Gary Chapman and Ross Campbell, The Five Love Languages of Children (Chicago: Northfield, 1997), 24.

ហើយ វេជ្ជបណ្ឌិត *ស៊ា* និយាយថា កូនរបស់អ្នកនឹងចាប់ផ្ដើមមានគំនិតយល់ដឹងពីព្រះជាម្ចាស់ មុនពេលដែលគេអាចសំដែងចេញឲ្យឃើញពីគំនិតរបស់គេពីការនោះបាន ។ "កូនរបស់អ្នកនឹងអាចយល់បានប្រសើរឡើងចំពោះគំនិតដែលទាក់ទងនឹងព្រះជាម្ចាស់ បើកូននោះបានឮគេនិយាយពីព្រះជាម្ចាស់កាលពីទើបនឹងកើតភ្លាម ។ នៅពេលដែលកូននោះមានអាយុ២ឆ្នាំ គេបានឮពាក្យគេនិយាយពីព្រះ និងពីព្រះយេស៊ូដែលគេនិយាយទាក់ទងនឹងសេចក្ដីស្រឡាញ់ និងការគាំពារថែរក្សារបស់ព្រះអង្គ ។ នៅពេលដែលគេមានអាយុ៣ឆ្នាំ គេមានអារម្មណ៍ទទួលបាននូវព្រះវត្តមានរបស់ព្រះជាម្ចាស់"។[៧]

ការសង្កេតមើលអំពីការឆ្លើយតបរបស់កូនខ្ញុំចំពោះរឿងស្ដីពីព្រះគ្រីស្ដបានបង្ហាញឲ្យខ្ញុំដឹងច្បាស់ពីការនេះ ។ *ឌីឡាន* ឥឡូវនេះអាយុ ៤ឆ្នាំ ហើយ នាងបានស្ដាប់រឿងនៅក្នុងព្រះគម្ពីរតាំងពីនាងអាយុមិនទាន់មួយឆ្នាំម្ល៉េះ ហើយនាងចេះចាំរឿងនោះច្បាស់ណាស់តាំងពីដើមដល់ចប់ ។ លើសពីនេះទៅទៀតនោះ ស្មារតីដ៏វាងវៃរបស់នាងមានការចាក់ឫសជ្រៅក្នុងសេចក្ដីពិតហើយនាងកំពុងតែចំរើនលូតលាស់ផ្នែកទំនាក់ទំនងដ៏ពិតប្រាកដជាមួយព្រះជាម្ចាស់ ។ ជួនកាលយើងសង្កេតឃើញនាងផ្អាកពាក់កណ្ដាលនូវអ្វីដែលនាងកំពុងធ្វើ ហើយនៅពេលដែលយើងសួរនាងថា ម៉េចបានជាផ្អាកអីចឹង នាងឆ្លើយថា នាងកំពុងតែ "ស្ដាប់ព្រះសូរសៀងព្រះជាម្ចាស់" ។ កូនរបស់យើងអាយុពីរឆ្នាំ ឈ្មោះ *ហ្សូ* តែងតែជាអ្នកផ្ដើមអធិស្ឋានមុនគេនៅឯតុអាហាររបស់យើង និងនៅមុនពេលចូលគេង ។ យប់មួយនោះកាលពីឆ្នាំទៅនាងភ្ញាក់ឡើងយំនៅពេលយប់ យំរកអ្នកយាមពេលយប់របស់យើង ហើយក៏នាំគ្នាអធិស្ឋានឲ្យគាត់ ។ នៅពេលព្រលឹមឡើងយើងបានដឹងថាអ្នកយាមរបស់យើងត្រូវទទួលគ្រោះថ្នាក់ចរាចរមានរបួស គឺនៅពេលយប់ដែលកូនរបស់

---

[៧] Sears, Christian Parenting, 332.

យើងសួររកគាត់នោះឯង ។ ដោយការសង្កេតឃើញពីការប្រាប់ឲ្យដឹងផ្នែកវិញ្ញាណរបៀបនេះតាមរយៈកូនតូចរបស់យើង ការនោះជួយជំរុញឲ្យយើងដឹងថា ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ដួងចិត្តនៃជីវិតគ្រួសាររបស់យើង ។ យើងអធិស្ឋាន និទានរឿង និងច្រៀងសរសើរព្រះជាមួយគ្នាដោយដឹងប្រាកដថា ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់កំពុងធ្វើការនៅក្នុងដួងចិត្តកូនរបស់យើង ។

> "សេចក្ដីទាំងនេះដែលអញបង្គាប់ដល់ឯងនៅថ្ងៃនេះ នោះត្រូវនៅជាប់ក្នុងចិត្តឯងចុះ ត្រូវឲ្យប្រិតប្រៀនសេចក្ដីទាំងនេះដល់កូនចៅឯង ព្រមទាំងនិយាយដំណាលក្នុងកាលដែលអង្គុយនៅក្នុងផ្ទះ ហើយដើរតាមផ្លូវក្នុងកាលដែលដេក ហើយក្រោកឡើងផង ត្រូវចងសេចក្ដីទាំងនេះជាប់នៅដៃឯងទុកជាទីសំគាល់ ហើយត្រូវធ្វើជាស្លាកនៅកណ្ដាលថ្ងាសឯងផង ក៏ត្រូវកត់នៅក្របទ្វារផ្ទះឯង ហើយនៅទ្វារកំផែងរបស់ឯងផង ។" (ចោទិយកថា ៦:៦-៩)

## កុមារជាមនុស្សពិសេសម្នាក់

ដោយយល់ថាកុមារទាំងឡាយជាមនុស្សពេញលក្ខណៈ នោះយើងត្រូវប្រព្រឹត្តចំពោះគេឲ្យសមនឹងតម្លៃលក្ខណៈពិសេសរបស់គេនោះឯង ។ វាជាការងាយចំពោះយើងក្នុងការបកស្រាយការយល់ឃើញរបស់កុមារថាមានតម្លៃទាប ឬមិនសូវសំខាន់ដូចជាមនុស្សចាស់ នៅក្នុងប្រព័ន្ធគ្រប់គ្រងនៅលោកិយ មនុស្សពេញវ័យកាន់អំណាច និងមានសិទ្ធិអំណាច ការបញ្ចេញគំនិតរបស់កុមារ ឬអ្នកក្រីក្រនោះងាយនឹងត្រូវគេបំភ្លេច ឬឲ្យតម្លៃទាប ។ ផ្ទុយទៅវិញ ព្រះជាម្ចាស់ផ្ដល់តួនាទីពិសេសចំពោះកុមារនៅក្នុងអាណាចក្ររបស់ព្រះអង្គ ហើយនៅក្នុងដំណឹងល្អទាំងមូល ព្រះយេស៊ូបញ្ជាក់ពីតម្លៃនៃ

"មនុស្សតូចៗទាំងនេះ" ។ នៅក្នុងដំណឹងល្អលោកម៉ាកុស យើងឃើញថា ព្រះយេស៊ូមានការឈ្វេងយល់ផ្ទុយពីពួកសិស្សរបស់ព្រះអង្គ ស្ដីពីកុមារទាំងឡាយដែលគេចូលមករកព្រះអង្គ ។ ព្រះអង្គមានបន្ទូលថា៖ "ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្សដូចវារាល់គ្នាដែរ"[៨] នៅក្នុងរឿងនៃអព្ភូតហេតុអស្ចារ្យដែលព្រះយេស៊ូបានផ្ដល់ចំណីអាហារដល់ហ្វូងមនុស្ស រឿងនោះកើតឡើងដោយសារអំណោយរបស់កុមារម្នាក់ដែលមាននំបុ័ង និងត្រីថ្វាយដល់ព្រះយេស៊ូ ហើយពេលនោះព្រះគ្រីស្ទប្រើអាហាររបស់កុមារនោះទៅចំអែតដល់មនុស្សពេញវ័យរាប់ពាន់នាក់ ។[៩] ការជ្រើសរើសដ៏មានឥទ្ធិពលធំធេងនោះ គឺការដែលព្រះអង្គយាងមកយកនិស្ស័យជាមនុស្សនៅក្នុងចំណោមយើងរាល់គ្នា ដោយព្រះអង្គឆ្លងកាត់កុមារភាពជាមុនដំបូង ព្រះអង្គមិនបានលេចមកឲ្យយើងឃើញជាមនុស្សពេញវ័យតែម្ដងទេ ព្រះអង្គមានបន្ទូលឲ្យតម្លៃសំខាន់ទៅលើការលូតលាស់និស្ស័យលក្ខណៈរបស់កុមារ ។

មនុស្សដែលមានភាពស្និតស្នាលជាមួយក្មេង តែងតែទាក់ទងជាមួយក្មេងក្នុងកំរិតនៃការយល់ដឹងរបស់កុមារនោះផ្ទាល់តែម្ដង ។ ជាទូទៅគឺចាប់ផ្ដើមយល់ពីកំរិតយល់ដឹងរបស់កុមារនៅពេលដែលចំណាយពេលលេងជាមួយកុមារនោះ ផ្ដល់ភាពកក់ក្ដៅ និងការកែតម្រង់ជួយឲ្យមនុស្សពេញវ័យយល់ឃើញពីគំនិតរបស់កុមារ និងធ្វើឲ្យមានការយល់ដឹងប្រាប់ដល់កុមារ ។ នៅពេលគ្រីស្ទបរិស័ទដែលជាមនុស្សពេញវ័យខំប្រឹងប្រែងយល់ពីកំរិតយល់ដឹងរបស់កុមារនៅក្នុងសហគមន៍របស់យើង ហើយបញ្ចូលគំនិតខ្លះរបស់កុមារទៅក្នុងការរស់នៅជាសហគមន៍ និងការថ្វាយបង្គំព្រះជាម្ចាស់

---

[៨] *ម៉ាកុស ១០:១៤*

[៩] *យ៉ូហាន ៦:៩*

របស់យើង នោះយើងកាន់តែអាចក្លាយដូចជាការរស់នៅមួយបែបនៃអាណាចក្ររបស់ព្រះជាម្ចាស់ ។ លោកគ្រូគង្វាល *ជីម ប្រិនណឺមែន* ពីក្រុមជំនុំ *ប៉ាសាឌីណា ម៉េណូណៃ* បានឲ្យយោបល់ថា៖ ``ក្រុមជំនុំអាចជាកន្លែងមួយដែលប្រសើរនោះ ដរាបណាជារឿយៗយើងព្រមអង្គុយស្តាប់នូវអ្វីដែលកូនរបស់យើងគេបង្រៀនយើង'' ។[១០]

កុមារមានលក្ខណៈទោល មិនមែនគ្រាន់តែជាមនុស្សមួយក្រុមប៉ុណ្ណោះទេ គឺគេមានលក្ខណៈពិសេសរៀងៗខ្លួនតែម្តង ។ ទំនុកតម្កើង ១៣៩ គឺជាប្រយោគមួយដ៏ល្អប្រណិតដែលថែងពីជំនាញដ៏ប៉ិនប្រសប់របស់ព្រះអាទិករដែលព្រះអង្គបាន ``ផ្សំគ្រឿង ឬផ្សំបញ្ចូលគ្នាឲ្យទារកលូតលាស់នៅក្នុងផ្ទៃរបស់ម្តាយគេនោះ'' ហើយដែលបានប្រកាសថា កុមារម្នាក់ៗព្រះអង្គបាន ``បង្កើតគេមកគួរឲ្យកោតសរសើរ និងគួរអស្ចារ្យ'' ពីស្នាព្រះហស្តរបស់ព្រះអង្គ ។ ការប្រដៅតម្រង់របស់យើង ត្រូវទទួលស្គាល់ពីលក្ខណៈទោលរបស់កុមារម្នាក់ៗ ។ អ្វីដែលខ្ញុំ ហើយនិងប្តីរបស់ខ្ញុំរៀនបានពីការបីបាច់ថែទាំកូននោះ គឺបានតាមរយៈការយល់ដឹងពីអារម្មណ៍ ប្រឌិតញាណរបស់កូនស្រីច្បងរបស់យើង ដែលមិនមែនតែងតែមានប្រយោជន៍រហូតចំពោះប្អូនស្រីរបស់នាងដែលមានលក្ខណៈក្លាហាន និងរួសរាយរាក់ទាក់នោះទេ ។

គ្រោងការដ៏គួរឲ្យចាប់អារម្មណ៍ចំពោះការ ``ស្វែងយល់'' ពីកូនរបស់យើងនោះគឺត្រូវតែស្វែងរកឲ្យឃើញពីលក្ខណៈទោលគ្មានពីរ ដែលគេបានទទួលពីព្រះជាម្ចាស់ដែលផ្តល់សេចក្តីស្រឡាញ់ដល់គេ ។ នេះគឺជាគំនិតដែលបានលើកឡើងនៅក្នុងសៀវភៅណែនាំពីរបៀបចិញ្ចឹមកូនរបស់គ្រីស្តបរិស័ទជាច្រើន ។ មានដំបូន្មានមួយបានថែងថា ``និយាយភាសាដែលបង្ហាញពីសេចក្តីស្រឡាញ់''[១១] រួមទាំងការបីបមថ្នមថែផ្នែករាងកាយ ពាក្យសំដីលើក

[១០] James E. Brenneman, Sermon 346, 27 February 2002.
[១១] Chapman and Campbell, *Five Love Languages*, 7.

ទឹកចិត្ត គុណភាពនៃពេលវេលា ការជូនអំណោយ (កាដូ) និងសកម្មភាពដែលបង្ហាញពីការបំរើ ។ ទំនៀមទម្លាប់នីមួយៗមានរបៀបជាផ្នែកៗរបស់ខ្លួនផ្ទាល់ក្នុងការបង្ហាញ និងការទទួលនូវសេចក្តីស្រឡាញ់ ឬយ៉ាងហោចណាស់ក៏មានការខុសប្លែកគ្នានៅក្នុងផ្នែកទាំងនោះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះមាតាបិតាទាំងអស់ ការដែលប្រសើរនោះគឺគេត្រូវសួរខ្លួនឯងថា៖ តើខ្ញុំពិតជាដឹងនូវរបៀបបង្ហាញសេចក្តីស្រឡាញ់ដល់កូនមែនដែរទេ? តើខ្ញុំបានសំគាល់ឃើញនូវរបៀបដែលកូនរបស់ខ្ញុំបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃជាប្រចាំដែរទេ? ការបង្ហឹកបង្ហាត់កូនក្នុងរបៀបមួយដែលគេគួរធ្វើ អាចធ្វើទៅបានសម្រេចប្រសើរបំផុតនៅពេលដែលយើងខំប្រឹងប្រែងស្គាល់ និងបញ្ជាក់យ៉ាងច្បាស់ពីអំណោយទានពិសេស និងបុគ្គលិកលក្ខណៈរបស់កូនយើង គឺដូចជាការដែលព្រះជាម្ចាស់ស្គាល់យើងច្បាស់យ៉ាងជិតស្និទ្ធ ហើយព្រះអង្គដឹងពីរបៀបដែលត្រូវបង្ហឹកបង្ហាត់យើងដូច្នោះដែរ ។ មានតែធ្វើយ៉ាងនោះទេទើបយើងអាចជួយពង្រឹងអំណោយទានរបស់គេ និងបង្ហាញពីសេចក្តីស្រឡាញ់ដ៏ធំធេងទៅដល់គេបាន ។

ការរៀនឲ្យស្គាល់ពីគំនិតជាក់លាក់ណាមួយរបស់កូនយើង នឹងជួយឲ្យយើងយល់ពីហេតុផលដែលនៅពីក្រោយទំនាស់ ដែលយើងតែងមានជាមួយគេនោះ ។ ឧទាហរណ៍ នៅពេលថ្មីៗនេះ ខ្ញុំបានយល់ឃើញនូវមូលហេតុសំខាន់នៃភាពតានតឹងរវាងខ្ញុំនិងកូនស្រីរបស់ខ្ញុំ គឺយើងមានល្បឿនខុសគ្នា ។ ខ្ញុំបោះជំហានលឿន និងសម្រេចចិត្តអ្វីមួយលឿន ឯកូនស្រីរបស់ខ្ញុំវិញនាងជាមនុស្សប្រើគំនិតគិតច្រើន នាងត្រូវការពេលគិតមុននឹងផ្លាស់ប្តូរអ្វីមួយនោះ ។ ឥឡូវនេះខ្ញុំយល់ ហើយខ្ញុំអាចសំគាល់ឃើញនូវភាពខុសប្លែកគ្នារវាងផ្នែកសីលធម៌ និងការដែលគ្រាន់តែខុសប្លែកគ្នារវាងបុគ្គលិកលក្ខណៈតែប៉ុណ្ណោះ ។ បើសិនមានទំនាស់រវាងបុគ្គលិកលក្ខណៈដែលមិនត្រូវគ្នានោះ គឺវាអាស្រ័យលើស្ថានភាព គឺខ្ញុំអាចព្យាយាមផ្តល់ឱកាសដល់

*ឌីឡាន* ជាកូនរបស់ខ្ញុំ ដោយព្រោះនាងជាមនុស្សម្នាក់ដែលមានការយល់ដឹងតិចតួច ហើយដោយការធ្វើបែបនោះ គឺបង្ហាញពីគំរូនៃការបន្ទាបខ្លួន និងការបង្ហាញពីសេចក្ដីស្រឡាញ់ដល់នាង ឬបើសិនជាខ្ញុំមិនអាចធ្វើការនោះបានទេ ខ្ញុំអាចព្យាយាមបង្រៀនឲ្យនាងចេះថ្លឹងថ្លែងយោងតាមស្ថានការណ៍ ប៉ុន្តែការធ្វើការនោះ គឺខ្ញុំធ្វើដោយចិត្តសុភាព ដោយយល់ដល់នាង ព្រោះនៅក្នុងពេលដែលនាងត្រូវប្ដូរការលូតលាស់ពីមួយដំណាក់ទៅមួយដំណាក់ទៀតនោះ ។

## កុមារជាមនុស្សដែលត្រូវការចំពោះការកែតម្រង់

ដើម្បីស្គាល់កូនរបស់យើងឲ្យបានច្បាស់ដូចដែលព្រះជាម្ចាស់ស្គាល់យើងនោះ យើងត្រូវតែទទួលស្គាល់ថា ព្រះជាម្ចាស់ជប់សូនបង្កើតគេឲ្យមានលក្ខណៈបែបហ្នឹង គឺមានលក្ខណៈពិសេស ហើយប្លែកពីអ្នកដទៃដែលមានសក្ដានុពលចំពោះទំនាក់ទំនងជាមួយព្រះជាម្ចាស់ និងជាមួយមនុស្ស ដូច្នេះចូរយើងយល់ថាគេជាមនុស្សបថុជ្ជនដូចយើង គឺត្រូវការការប្រោសលោះដូចគ្នាដែរ ។ សុភាសិត ២២:១៥ ចែងថា៖ "សេចក្ដីចំកួតរមែងនៅជាប់ក្នុងចិត្តរបស់កូនក្មេង" ។ ចំពោះអ្នកដែលមិនមានកូនអាយុពីរ ឬបីឆ្នាំ ដូចយើងមិនដឹងពីការនេះទេ ។ ជួនកាលសេចក្ដីចំកួតនោះ ខ្ញុំសង្កេតឃើញនៅក្នុងការប្រព្រឹត្តិរបស់កូនខ្ញុំ ដូចជាការលោតចុះលោតឡើងនៅលើស៊ីក្លូ ពេលដែលស៊ីក្លូកំពុងតែធ្វើដំណើរ ឬក៏រត់លេងលើថ្នល់ ។ ប៉ុន្តែពេលខ្លះ បញ្ហានោះទាក់ទងលើផ្នែកសីលធម៌រស់នៅ ។ ការប្រដៅតម្រង់ ឬការដឹកនាំឲ្យទាន់ពេលដែលត្រូវកែតម្រូវ នោះគឺជាគំនិតមួយដ៏ល្អបំផុតចំពោះតួនាទីរបស់យើងដែលជាឪពុកម្ដាយនោះ ។ ប៉ុន្តែការនោះគឺជាការចាំបាច់បំផុតដើម្បីដឹកនាំកូនឲ្យទៅតាមអំណោយទានប្រកបដោយសក្ដានុពលដែលព្រះជាម្ចាស់ប្រទានមកឲ្យកូនយើង និងនាំឲ្យគេបានទទួលព្រះពរចំពោះការដែលដើរជាប់ជាមួយនឹងព្រះជាម្ចាស់ ។

នៅក្នុងអត្ថបទនេះ ខ្ញុំគ្មានបំណងដើម្បីសរសេរពីរបៀបប្រដៅតម្រង់កូនចៅដ៏ជាក់លាក់ណាមួយនោះឡើយ ។ តែទោះជាយ៉ាងណាក៏ដោយ នៅគ្រប់ផ្នែកនៃការប្រដៅតម្រង់កូនចៅរបស់យើង ត្រូវទុកឱកាសសំរាប់ប្រាស្រ័យទាក់ទងជាមួយកូន ដោយការបន្តសិក្សាឲ្យស្គាល់ពីលក្ខណៈនិស្ស័យរបស់កូន នោះជាការសំខាន់ណាស់ ។ ការខំប្រឹងប្រែងគាំទ្រដែលនាំឲ្យយើងបានស្គាល់ពីលក្ខណៈនិស្ស័យរបស់កូនយើង នឹងជួយសម្រួលដល់ការប្រដៅតម្រង់កូនបានមួយចំណែកដែរ ។ ដ្បិតការប្រាស្រ័យទាក់ទងនេះឯងដែលផុសចេញពីការទំនាក់ទំនងបង្កើតឲ្យមានការទុកចិត្តបែបនេះនឹងជួយយើងបាន គឺ:

- វិធានការប្រដៅតម្រង់ នៅក្នុងគោលដៅទាំងអស់នៃការដាក់ពិន័យគឺ: ត្រូវឲ្យកូនយល់ និងពង្រឹងចរិតលក្ខណៈដែលកោតខ្លាចព្រះនៅក្នុងគំនិតរបស់កូន ។ [១២]
- បង្ហាញឲ្យកូនរបស់យើងឃើញច្បាស់ ផ្តល់ឲ្យគេមានជំរើស និងឲ្យគេឃើញពីផលវិបាកតាមរបៀបមួយដែលគេអាចប្រើគំនិតយល់បាន ។

ចូរបង្កើតរចនាសម្ព័ន និងលក្ខខ័ណ្ឌនានានៅក្នុងផ្ទះរបស់យើងដែលអាចជំរុញលើកទឹកចិត្តកូនរបស់យើងឲ្យមានចិត្តចង់មានឥរិយាបថមួយដែលជាទីគួរឲ្យប្រាថ្នាចង់បាន ។ ការនេះនឹងជួយឲ្យយើងរក្សានូវឥរិយាបថដ៏ត្រឹមត្រូវក្នុងការកែតម្រូវស្តីប្រដៅកូនរបស់យើង ប្រយោជន៍មិនឲ្យយើងប្រព្រឹត្តដោយប្រើកំហឹង តែត្រូវឲ្យយើងមានចិត្តធូរវិញ ដែលឆ្លុះបញ្ចាំងពីការដែលព្រះជាម្ចាស់ប្រដៅតម្រង់បុត្រធីតារបស់ព្រះអង្គ ។

---

[១២] *សូមមើល ហេព្រើរ ១២:១០-១១*

## អំណាចនៃឥទ្ធិពលរបស់ឪពុកម្តាយ

យើងបានឃើញថាព្រះជាម្ចាស់មានព្រះបន្ទូលជាច្រើនស្តីអំពីកុមារ គឺព្រះជាម្ចាស់ជាអ្នកបង្កើតគេមកជារូបឆ្លុះរបស់ព្រះអង្គ ជាមនុស្សដែលមានបុគ្គលិកលក្ខណៈទាំងអស់ មាននិស្ស័យលក្ខណៈជាកុមារភាព ហើយព្រះអង្គបានបង្កើតគេមកតាមបែបផែនមួយដែលមានសមត្ថភាពក្នុងការធ្វើទំនាក់ទំនង ប៉ុន្តែទំនាក់ទំនងនោះត្រូវការការប្រោសលោះ ដើម្បីឲ្យគេបានរស់នៅក្នុងទំនាក់ទំនងដ៏សុចរិតត្រឹមត្រូវជាមួយព្រះជាម្ចាស់ និងជាមួយអ្នកជិតខាងខ្លួន។ ដោយយោងតាមការទាំងនេះ វេជ្ជបណ្ឌិត *ស៊ា* បបួលយើងឲ្យចាប់យកគំនិតដែលយើងត្រូវខំសិក្សាពីកូនរបស់យើង ប្រៀបដូចជាអ្នកថែសួនស្គាល់ពីរុក្ខជាតិទាំងឡាយដែលដុះនៅក្នុងសួនរបស់គាត់ដូច្នេះដែរ ។ ការនេះមានន័យថា ត្រូវរៀនឲ្យស្គាល់របៀបត្រឹមត្រូវក្នុងការបីបាច់ចិញ្ចឹមកូនរបស់យើង ហើយត្រូវប្រយ័ត្នពីឧបសគ្គទាំងឡាយដែលធ្វើឲ្យកូនរបស់យើងងាយរងគ្រោះនោះ ។ ដោយប្រើវិធីនៃការប្រដៅតម្រង់របៀបនេះ ការណែនាំរបស់យើងមិនធូររលុងពេក និងមិនតឹងតែងខ្លាំងពេក ពីព្រោះយើងពិនិត្យមើលរបៀបប្រដៅតម្រង់របស់យើងដោយប្រាជ្ញា និងដោយភ្នែកដែលពោរពេញដោយព្រះគុណរបស់ព្រះជាម្ចាស់ ដូចដែលព្រះជាម្ចាស់ទតមើលមកយើង ហើយព្រះអង្គដឹកនាំការទាំងនោះតាមគតិបណ្ឌិតរបស់ព្រះអង្គដែរ ។